# លិខិតទីមួយរបស់ លោកសិលា

## ពាក្យលំនាំ

លោកសិលាបានសរសេរលិខិតទីមួយនេះ ផ្ញើជូនគ្រីស្តបរិស័ទដែលបែកខ្ញែកគ្នា តាមតំបន់ទាំងប្រាំនៅមជ្ឈិមបូព៌ា។ គ្រីស្តបរិស័ទទាំងនោះកកើតឡើង ដោយសារប៉ូលបានប្រកាសផ្សាយដំណឹងល្អ។ ប្រហែលជាលោកសិលាតែងលិខិតនេះ កាលលោកនៅក្រុងរ៉ូម ដែលលោកឲ្យឈ្មោះថា «បាប៊ីឡូន»(៥.១៣) នៅគ.ស.៦៤។

### គោលបំណង

នៅគ្រានោះ គ្រីស្តបរិស័ទត្រូវគេប្រមាថមើលងាយ និងត្រូវគេធ្វើទុក្ខបៀតបៀនទៀតផង។ ហេតុនេះគ្រីស្តទូតសិលា មានបំណងដាស់តឿនគ្រីស្តបរិស័ទ ដែលខ្ចាត់ខ្ចាយក្នុងពិភពលោក ឲ្យមានជំនឿកាន់តែមាំមួនលើព្រះយេស៊ូគ្រីស្តស្របតាមពិធីជ្រមុជទឹកដែលគេបានទទួល។ ជំនឿនេះ នឹងផ្ដល់ឲ្យគេមានចិត្តសង្ឃឹមដ៏មុះមុតគ្រប់កាលៈទេសៈ និងមានជ័យជម្នះលើឧបសគ្គនានា។ រីឯទុក្ខលំបាកដែលគ្រីស្តបរិស័ទជួបប្រទះ ធ្វើឲ្យគេរួមជាមួយព្រះគ្រីស្តគម្ពីរដែលទុក្ខលំបាកដែរ។

## សេចក្ដីផ្ដើម

១ខ្ញុំ សិលា ជាគ្រីស្ដទូត*របស់ព្រះយេស៊ូគ្រី
១ស្ដ សូមជម្រាបមកបងប្អូនដែលព្រះជាម្ចាស់
បានជ្រើសរើស ហើយដែលបែកខ្ញែកគ្នាទៅរស់
ជាអាណិកជន នៅស្រុកប៉ុនតុស ស្រុកកាឡាទី
ស្រុកកាប៉ាដូស ស្រុកអាស៊ី និងស្រុកប៊ីធីនី។ ២
ព្រះជាម្ចាស់ជាព្រះបិតាបានជ្រើសរើសបងប្អូន
តាមគម្រោងការដែលព្រះអង្គគ្រោងទុកពីមុន
មក ដោយព្រះវិញ្ញាណប្រោសបងប្អូនឲ្យបាន
វិសុទ្ធ* ដើម្បីឲ្យបងប្អូនស្ដាប់បង្គាប់ព្រះយេស៊ូ
គ្រីស្ដ* និងឲ្យព្រះអង្គប្រោះព្រះលោហិតរបស់
ព្រះអង្គ លើបងប្អូន[ក]។សូមព្រះជាម្ចាស់ប្រណី
សន្ដោស និងប្រទានសេចក្ដីសុខសាន្ដមកបង
ប្អូនយ៉ាងបរិបូណ៌។

## សេចក្ដីសង្ឃឹម

៣សូមសរសើរតម្កើងព្រះជាម្ចាស់ ជាព្រះ
បិតារបស់ព្រះយេស៊ូគ្រីស្ដ* ជាព្រះអម្ចាស់នៃ
យើង។ ព្រះជាម្ចាស់បានប្រោសយើងឲ្យកើត
ជាថ្មីដោយប្រោសព្រះយេស៊ូគ្រីស្ដ* ឲ្យមាន
ព្រះជន្មរស់ឡើងវិញ ស្របតាមព្រះហឫទ័យ
មេត្តាករុណាដ៏លើសលប់របស់ព្រះអង្គ ដូច្នេះ
យើងមានសេចក្ដីសង្ឃឹម ដែលមិនចេះសាប
សូន្យ ៤ហើយយើងនឹងទទួលមត៌ក[ខ]ដែលមិន
ចេះរលួយ មិនចេះសៅហ្មង មិនចេះស្រពោន។
ព្រះជាម្ចាស់បម្រុងទុកមត៌កនេះ ឲ្យបងប្អូននៅ
ស្ថានបរមសុខ* ៥ហើយឫទ្ធានុភាពរបស់ព្រះ
អង្គថែរក្សាបងប្អូនដោយសារជំនឿ ដើម្បីឲ្យបង
ប្អូនទទួលការសង្គ្រោះ ដែលព្រះអង្គបានរៀបចំ
ទុកជាស្រេច ហើយដែលទ្រង់នឹងសម្ដែងនៅ
គ្រាចុងក្រោយបំផុត។

៦ហេតុនេះហើយបានជា បងប្អូនមានចិត្តរីក
រាយយ៉ាងខ្លាំង ទោះបីពេលនេះបងប្អូនព្រួយ
ចិត្តដោយជួបនឹងទុក្ខលំបាកផ្សេងៗ ក្នុងមួយរ
យៈពេលខ្លីក៏ដោយ។ ៧ទុក្ខលំបាកទាំងនេះនឹង
លត់ដំ[គ]ជំនឿរបស់បងប្អូន ឲ្យមានតម្លៃលើស
មាស ដែលតែងតែរលាយសូន្យនោះទៅទៀតគឺ
មាសដែលសម្រាំងក្នុងភ្លើង។ នៅថ្ងៃដែលព្រះ
យេស៊ូគ្រីស្ដសម្ដែងខ្លួន ឲ្យមនុស្សលោកឃើញ
ជំនឿរបស់បងប្អូន នឹងទទួលការសរសើរទទួល
សិរីរុងរឿង និងកិត្តិយសជាមិនខាន។ ៨បងប្អូន
មិនដែលបានឃើញព្រះអង្គទេ តែបងប្អូន
ស្រឡាញ់ព្រះអង្គ ទោះបីបងប្អូននៅតែពុំទាន់
ឃើញព្រះអង្គក្ដី ក៏បងប្អូនជឿលើព្រះអង្គហើយ
មានអំណរសប្បាយដ៏រុងរឿង រកថ្លែងពុំបាន
៩ព្រោះបងប្អូនបានទទួលការសង្គ្រោះ សម្រាប់
ព្រលឹងខ្លួនដែលជាទីដៅនៃជំនឿរបស់បងប្អូន។

១០ ព្យាការី*ដែលថ្លែងព្រះបន្ទូល* អំពីព្រះ
ហឫទ័យប្រណីសន្ដោស របស់ព្រះជាម្ចាស់
ចំពោះបងប្អូនបាននាំគ្នាស្រាវជ្រាវ និងរិះរកចង់
ដឹងអំពីការសង្គ្រោះនេះ។ ១១ព្រះវិញ្ញាណរបស់
ព្រះគ្រីស្ដ ដែលគង់នៅក្នុងព្យាការីទាំងនោះ
បានបញ្ជាក់ប្រាប់ជាមុន អំពីទុក្ខលំបាករបស់
ព្រះគ្រីស្ដ និងអំពីសិរីរុងរឿងដែលព្រះអង្គនឹង
ទទួលតាមក្រោយ។ ពួកលោកក៏បានរិះគិតចង់
ដឹងថា តើព្រឹត្តិការណ៍នេះនឹងកើតមាននៅ

ជំនាន់ណាក្នុងកាលៈទេសៈណា។ ១២ព្រះជា
ម្ចាស់បានសម្ដែងឲ្យព្យាការីទាំងនោះ ដឹងថា
សេចក្ដីដែលពួកលោកថ្លែងមិនមែនសម្រាប់ពួក
លោកទេ គឺសម្រាប់បងប្អូនវិញ។ ឥឡូវនេះពួក
អ្នកផ្សព្វផ្សាយដំណឹងល្អ*បាននាំដំណឹង មក
ប្រាប់បងប្អូនអំពីសេចក្ដីទាំងនោះ ក្រោមការ
ណែនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ* ដែលព្រះជា
ម្ចាស់បានចាត់ពីស្ថានបរមសុខមក។ សូម្បីតែ
ពួកទេវទូត* ក៏ប្រាថ្នាចង់យល់ជម្រៅនៃសេចក្ដី
ទាំងនោះដែរ។

## ការទូន្មានឲ្យមានជីវិតដ៏វិសុទ្ធ

១៣ហេតុនេះ សូមបងប្អូនប្រុងប្រៀបចិត្ត
គំនិតឲ្យមែនទែន កុំភ្លេចខ្លួនឲ្យសោះ ត្រូវមាន
ចិត្តសង្ឃឹមទាំងស្រុងថា នឹងទទួលព្រះ
អំណោយទានដែលព្រះជាម្ចាស់ប្រោសប្រទាន
ឲ្យបងប្អូន នៅថ្ងៃព្រះយេស៊ូគ្រីស្ត*នឹងសម្ដែង
ព្រះអង្គឲ្យមនុស្សលោកឃើញ។ ១៤ចូរធ្វើដូច
កូនដែលចេះស្ដាប់បង្គាប់ គឺមិនត្រូវធ្វើតាមចិត្ត
ប៉ងប្រាថ្នា ដែលបងប្អូនធ្លាប់មានកាលមិនទាន់
ស្គាល់ព្រះអង្គ[ឃ]នោះឡើយ ១៥ផ្ទុយទៅវិញព្រះ
អង្គដែលបានត្រាស់ហៅបងប្អូន ទ្រង់វិសុទ្ធ*
យ៉ាងណាបងប្អូនក៏ត្រូវតែវិសុទ្ធ* ក្នុងគ្រប់កិច្ច
ការ ដែលបងប្អូនប្រព្រឹត្ត យ៉ាងនោះដែរ ១៦ ដ្បិត
ក្នុងគម្ពីរមានចែងទុកថា៖ «អ្នករាល់គ្នាត្រូវតែ
វិសុទ្ធ* ព្រោះយើងវិសុទ្ធ»[ង]។

១៧មួយវិញទៀត ប្រសិនបើបងប្អូនអង្វររក
ព្រះជាម្ចាស់ក្នុងឋានៈព្រះអង្គជាព្រះបិតា ចូររស់
នៅដោយគោរពកោតខ្លាចព្រះអង្គ ក្នុងពេល
ដែលបងប្អូនស្នាក់នៅលើផែនដីនេះ ដ្បិតព្រះ
អង្គនឹងវិនិច្ឆ័យមនុស្ស តាមអំពើដែលម្នាក់ៗ
បានប្រព្រឹត្តឥតរើសមុខនរណាឡើយ។ ១៨បង
ប្អូនជ្រាបស្រាប់ហើយថា ព្រះជាម្ចាស់បាន
លោះបងប្អូន ឲ្យរួចពីរបៀបរស់នៅដ៏ឥតន័យ
ដែលជាដំណែល តពីបុព្វបុរស*របស់បងប្អូន
មិនមែនដោយសារអ្វីៗ ដែលតែងតែរលាយ
សាបសូន្យទៅដូចជាមាសឬប្រាក់ទេ ១៩គឺ
ដោយសារព្រះលោហិតដ៏ថ្លៃវិសេស របស់ព្រះ
គ្រីស្ត* ដែលប្រៀបបាននឹងកូនចៀមដ៏ល្អឥត
ខ្ចោះ ឥតស្លាកស្នាម។ ២០ព្រះជាម្ចាស់បាន
ជ្រើសតាំងព្រះគ្រីស្តមុនកំណើតពិភពលោកទៅ
ទៀតហើយបានបង្ហាញព្រះអង្គ ឲ្យមនុស្ស
លោកឃើញ នៅគ្រាចុងក្រោយនេះ ព្រោះតែ
បងប្អូន។ ២១តាមរយៈព្រះគ្រីស្តបងប្អូនជឿលើ
ព្រះជាម្ចាស់ ដែលបានប្រោសព្រះអង្គឲ្យមាន
ព្រះជន្មរស់ឡើងវិញ ហើយប្រទានសិរីរុងរឿង
មកព្រះអង្គ ដើម្បីឲ្យបងប្អូនមានជំនឿ និងមាន
សង្ឃឹមលើព្រះជាម្ចាស់។

២២បងប្អូនបានជម្រះព្រលឹង ឲ្យបាន
បរិសុទ្ធ* ដោយស្ដាប់តាមសេចក្ដីពិតដើម្បីឲ្យ
បងប្អូនចេះស្រឡាញ់គ្នាយ៉ាងស្មោះស្ម័គ្រ ដូច
បងប្អូនបង្កើត។ ចូរស្រឡាញ់គ្នាទៅវិញទៅមក
ឲ្យអស់ពីចិត្តទៅ។ ២៣ព្រះជាម្ចាស់បានប្រោស
បងប្អូនឲ្យកើតជាថ្មី មិនមែនដោយពូជដែល
តែងតែរលួយទេ គឺដោយពូជមិនចេះរលួយ
ដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះ
បន្ទូលនេះផ្ដល់ជីវិត ហើយនៅស្ថិតស្ថេរជា
ដរាប ២៤ដ្បិត

*មនុស្សគ្រប់ៗរូបប្រៀបបាននឹងស្មៅ*
*រីឯសិរីរុងរឿងទាំងប៉ុន្មានរបស់គេ*
*ប្រៀបបាននឹងផ្កាស្មៅ*
*តែងតែក្រៀម ហើយផ្កាក៏រុះរោយដែរ*
២៥ *ប៉ុន្តែព្រះបន្ទូលរបស់ព្រះអម្ចាស់*
*នៅស្ថិតស្ថេរអស់កល្បជានិច្ច*[ច] ។

ព្រះបន្ទូលនេះគឺជាដំណឹងល្អ* ដែលគេ
បាននាំយកមកជូនបងប្អូន។

## ប្រជារាស្ត្រដ៏វិសុទ្ធ

២ ១ហេតុនេះ ចូរបងប្អូនលះបង់ការអាក្រក់
គ្រប់យ៉ាងលះបង់ល្បិចកិច្ចកលទាំងប៉ុន្មាន ការ
លាក់ពុតចិត្តច្រណែនឈ្នានីស និងការនិយាយ
ដើមគេគ្រប់យ៉ាងនោះចោលទៅ! ២ចូរប្រាថ្នា
ចង់បានព្រះបន្ទូល ដូចទារកដែលទើបនឹងកើត
ប្រាថ្នាចង់បានទឹកដោះសុទ្ធ ដើម្បីឲ្យបងប្អូន
បានចម្រើនឡើងតាមរយៈព្រះបន្ទូលនេះ និង
ទទួលការសង្គ្រោះ ៣បើបងប្អូនពិតជាបានគ្រេប
ជញ្ជក់ដឹងថា ព្រះអម្ចាស់មានព្រះហឫទ័យ
សប្បុរសមែននោះ![ឆ]

៤សូមបងប្អូនចូលមកជិតព្រះគ្រិស្តជា
សិលាដ៏មានជីវិត ជាសិលាដែលមនុស្សលោក
បានបោះបង់ចោល តែព្រះជាម្ចាស់បានរើស
យកព្រោះទ្រង់ឈ្វេងយល់ថា មានតម្លៃវិសេ
ស។ ៥រីឯបងប្អូនវិញ បងប្អូនប្រៀបបាននឹងថ្មដ៏
មានជីវិតដែរ ដូច្នេះចូរផ្គុំគ្នាឡើងកសាងជាព្រះ
ដំណាក់របស់ព្រះវិញ្ញាណធ្វើជាក្រុមបូជាចារ្យដ៏
វិសុទ្ធ ដើម្បីថ្វាយយញ្ញបូជាខាងវិញ្ញាណជាទី
គាប់ព្រះហឫទ័យព្រះជាម្ចាស់ តាមរយៈព្រះ
យេស៊ូគ្រីស្ត* ៦ដ្បិតក្នុងគម្ពីរមានចែងថា៖

*«យើងបានរើសយកថ្មគ្រឹះមួយដ៏សំខាន់*
*ហើយមានតម្លៃ*
*យើងដាក់ថ្មនោះនៅក្រុងស៊ីយ៉ូន។*
*អ្នកណាជឿលើថ្មនោះ*
*អ្នកនោះមុខជាមិនត្រូវខកចិត្តឡើយ»*[ជ] ។

៧ថ្មនេះមានតម្លៃវិសេសសម្រាប់បងប្អូនជា
អ្នកជឿ។ រីឯអ្នកដែលមិនជឿវិញ

*«ថ្មដែលពួកជាងសង់ផ្ទះបោះបង់ចោល*
*បានត្រឡប់មកជាថ្មគ្រឹះដ៏សំខាន់បំផុត*[ឈ]
៨ *ជាថ្មដែលនាំឲ្យគេជំពប់ដួល*
*ជាសិលាដែលនាំឲ្យគេរវាតចិត្ត*
*បាត់ជំនឿ»*[ញ] ។

អ្នកទាំងនោះជំពប់ដួល ដូចព្រះជាម្ចាស់
បានគ្រោងទុកមកស្រាប់ មកពីគេពុំព្រមជឿព្រះ
បន្ទូល ៩រីឯបងប្អូនវិញ បងប្អូនជាពូជសាសន៍
ដែលព្រះអង្គបានជ្រើសរើស ជាក្រុមបូជាចារ្យ
របស់ព្រះមហាក្សត្រ ជាជាតិសាសន៍ដ៏វិសុទ្ធជា
ប្រជារាស្ត្រ ដែលព្រះជាម្ចាស់បានយកមកធ្វើជា
កម្មសិទ្ធិផ្ទាល់របស់ព្រះអង្គ ដើម្បីឲ្យបងប្អូន
ប្រកាសដំណឹង អំពីស្នាព្រះហស្តដ៏អស្ចារ្យ[ដ]
របស់ព្រះអង្គដែលបានហៅបងប្អូន ឲ្យចេញពីទី
ងងឹត មកកាន់ពន្លឺដ៏រុងរឿងរបស់ព្រះអង្គ។ ១០ពី
ដើមបងប្អូនមិនមែនជាប្រជារាស្ត្ររបស់ព្រះជា
ម្ចាស់ទេ តែឥឡូវនេះបងប្អូនជាប្រជារាស្ត្ររបស់
ព្រះអង្គហើយ ពីដើមបងប្អូនពុំបានទទួលព្រះ
ហឫទ័យមេត្តាករុណាទេ តែឥឡូវនេះ បងប្អូន
បានទទួលព្រះហឫទ័យមេត្តាករុណាហើយ[ឋ]។

## របៀបរស់នៅ
## នៃអ្នកបម្រើរបស់ព្រះជាម្ចាស់

១១បងប្អូនជាទីស្រឡាញ់អើយ ខ្ញុំសូមទូន្មាន
បងប្អូនជាជនបរទេស និង ជាអ្នកស្នាក់នៅជា
បណ្ដោះអាសន្ន[ឌ]ក្នុងលោកនេះថា កុំបណ្ដោយ
ខ្លួនទៅតាមតណ្ហា[ឍ] ដែលតែងតែប្រឆាំងនឹង
ព្រលឹងនោះឡើយ។ ១២ត្រូវកាន់កិរិយាមារយាទ
ឲ្យបានថ្លៃថ្នូរ នៅក្នុងចំណោមសាសន៍ដទៃ។
ដូច្នេះ ត្រង់ចំណុចណាដែលគេចោទថាបងប្អូន
ប្រព្រឹត្តអាក្រក់ គេបែរជាឃើញអំពើល្អរបស់បង
ប្អូនទៅវិញ ហើយនៅថ្ងៃដែលព្រះជាម្ចាស់យាង
មក[ណ] គេនឹងលើកតម្កើងសិរីរុងរឿងរបស់ព្រះ
អង្គថែមទៀតផង។

១៣សូមគោរពចុះចូលអំណាចនានា នៅលើ
ផែនដីនេះដោយយល់ដល់ព្រះអម្ចាស់ គឺត្រូវ
គោរពចុះចូលព្រះរាជា ក្នុងឋានៈលោកជាអ្នក
មានអំណាចធំជាងគេ ១៤ត្រូវគោរពចុះចូលនឹង
លោកទេសាភិបាលទាំងឡាយ ក្នុងឋានៈលោក
ជាតំណាងរបស់ព្រះរាជា ដែលទ្រង់ចាត់ឲ្យមក
ធ្វើទោសអស់អ្នកដែលប្រព្រឹត្តអំពើអាក្រក់ និង
សរសើរអស់អ្នកដែលប្រព្រឹត្តអំពើល្អ។ ១៥ព្រះ
ជាម្ចាស់សព្វព្រះហឫទ័យ ឲ្យបងប្អូនបំបិទមាត់
ពួកមនុស្សខ្លៅ ដោយបងប្អូនប្រព្រឹត្តអំពើល្អ១៦
ឲ្យសមនឹងឋានៈជាមនុស្សមានសេរីភាព ក៏ប៉ុន្តែ
កុំប្រើសេរីភាពនេះ ដើម្បីគ្របបាំងអំពើអាក្រក់
ឡើយ គឺត្រូវប្រព្រឹត្តឲ្យសមនឹងឋានៈបងប្អូន
ដែលជាអ្នកបម្រើរបស់ព្រះជាម្ចាស់។ ១៧ចូរ
គោរពមនុស្សគ្រប់ៗរូប ចូរស្រឡាញ់បងប្អូនរួម
ជំនឿ ចូរគោរពកោតខ្លាចព្រះជាម្ចាស់ និង
គោរពព្រះរាជាផង។

## គំរូអំពីទុក្ខលំបាករបស់ព្រះគ្រីស្ត

១៨បងប្អូនដែលជាអ្នកបម្រើអើយ! ត្រូវ
គោរពចុះចូលនឹងម្ចាស់របស់ខ្លួន ដោយគោរព
កោតខ្លាចទាំងស្រុង មិនត្រឹមតែគោរពចុះចូល
នឹងម្ចាស់ណាដែលល្អ និងមានចិត្តសប្បុរស
ប៉ុណ្ណោះទេ គឺត្រូវចុះចូលនឹងម្ចាស់ដែលកាច
ផងដែរ។ ១៩បើមានបងប្អូនណាម្នាក់រងទុក្ខ
លំបាកដោយអយុត្តិធម៌ ហើយស៊ូទ្រាំព្រោះ
យល់ដល់ព្រះជាម្ចាស់ តោងចាត់ទុកថាព្រះអង្គ
ប្រណីសន្ដោស ដល់បងប្អូននោះហើយ។
២០ប្រសិនបើ បងប្អូនស៊ូទ្រាំរងទារុណកម្មមកពី
បានប្រព្រឹត្តអំពើអាក្រក់ណាមួយ បងប្អូនគ្មាន
កិត្តិយសអ្វីទេ! ផ្ទុយទៅវិញ ប្រសិនបើ បងប្អូន
បានប្រព្រឹត្តអំពើល្អ តែស៊ូទ្រាំនឹងទុក្ខលំបាក
នោះមកពីព្រះជាម្ចាស់ប្រណីសន្ដោស ដល់បង
ប្អូន[ត]។

២១ ព្រះអង្គត្រាស់ហៅបងប្អូនមក
ឲ្យរងទុក្ខលំបាកយ៉ាងនេះ
ព្រោះព្រះគ្រីស្ដ* ក៏បានរងទុក្ខលំបាក
សម្រាប់បងប្អូន ទុកជាគំរូឲ្យ
បងប្អូនដើរតាមគន្លងរបស់ព្រះអង្គដែរ។
២២ ព្រះអង្គពុំដែលបានប្រព្រឹត្តអំពើបាបសោះ
ហើយក៏ពុំដែលមានព្រះបន្ទូលវៀចវេរណា
ចេញពីព្រះឱស្ឋរបស់ព្រះអង្គឡើយ[ថ]។
២៣ ទោះបីគេជេរប្រមាថព្រះអង្គ
ក៏ព្រះអង្គមិនតបតទៅគេវិញដែរ
ព្រះអង្គបានរងទុក្ខលំបាក

*តែព្រះអង្គពុំបានគំរាមកំហែងគេវិញទេ*
*ព្រះអង្គផ្ញើជីវិតទៅលើព្រះជាម្ចាស់*
*ដែលទ្រង់វិនិច្ឆ័យដោយយុត្តិធម៌។*
២៤ *ព្រះគ្រីស្ត* បានផ្ទុកបាប* របស់យើង*
*ក្នុងព្រះកាយរបស់ព្រះអង្គ*
*ដែលជាប់លើឈើឆ្កាង*
*ដើម្បីឲ្យយើងលែងជំពាក់ជំពិន*
*នឹងបាបតទៅមុខទៀត*[ទ]
*ហើយឲ្យយើងមានជីវិត*
*ដោយប្រព្រឹត្តតែអំពើសុចរិត* ។*
*បងប្អូនបានជាសះស្បើយដោយសារ*
*ស្នាមរបួសរបស់ព្រះអង្គ*[ធ]
២៥ *ដ្បិតបងប្អូនប្រៀបដូចជាចៀមដែលវង្វេង*
*តែឥឡូវនេះ បងប្អូនបានវិលត្រឡប់មករក*
*អ្នកគង្វាល និងអ្នកថែរក្សាព្រលឹង*
*របស់បងប្អូនវិញហើយ។*

## ទំនាក់ទំនងរវាងស្វាមី និង ភរិយា

១រីឯបងប្អូនស្ត្រីៗ ដែលមានស្វាមីក៏ដូច្នោះ
៣ដែរ ត្រូវគោរពចុះចូលនឹងស្វាមីរៀងៗខ្លួន
ដើម្បីឲ្យកិរិយាមារយាទរបស់បងប្អូនទាក់ទាញ
ចិត្តស្វាមីខ្លះ ដែលមិនជឿព្រះបន្ទូលឲ្យបាន
ស្គាល់ព្រះអង្គ ដោយមិនបាច់បញ្ចេញពាក្យសំដី
ទេ ២គឺគេគ្រាន់តែឃើញបងប្អូនមានកិរិយា
បរិសុទ្ធ*និងចេះគោរពកោតខ្លាច។ ៣កុំតុបតែង
ខ្លួនតែសំបកក្រៅដូចជាក្រងសក់ពាក់មាស ឬក៏
ពាក់អាវល្អប្រណីតនោះឡើយ ៤តែត្រូវតុបតែង
ខាងក្នុងជម្រៅចិត្តរបស់បងប្អូន ដោយគ្រឿង
លំអដែលមិនចេះរលាយហើយមានតម្លៃដ៏
លើសលប់នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់នោះ
វិញ គឺមានចិត្តស្លូតបូត ស្រគត់ស្រគំ។ ៥នៅ
ជំនាន់ដើម ស្ត្រីៗដ៏វិសុទ្ធ*ដែលសង្ឃឹមលើព្រះ
ជាម្ចាស់ តែងកាន់ចិត្តគំនិតយ៉ាងនេះឯង គឺបាន
តុបតែងខ្លួនដោយការគោរពចុះចូលនឹងស្វាមី
រៀងៗខ្លួន ៦ដូចជាលោកស្រីសារ៉ា ដែលបាន
ស្ដាប់បង្គាប់លោកអប្រាហាំទាំងហៅលោកថា
«លោកម្ចាស់»ផង។ ប្រសិនបើបងប្អូនប្រព្រឹត្ត
ល្អហើយមិនភ័យខ្លាចអ្វីទេនោះ បងប្អូននេះ
ហើយជាពូជពង្សរបស់គាត់។
៧រីឯបងប្អូនដែលជាស្វាមី ក៏ដូច្នោះដែរ ម្នា
ក់ៗត្រូវរួមរស់ជាមួយភរិយារបស់ខ្លួន ដោយ
យល់ថា ស្ត្រីៗជាមនុស្សទន់ខ្សោយជាងខ្លួន។
ត្រូវគោរពនាង ទុកដូចជាអ្នកត្រូវរួមទទួលជីវិត
ដែលព្រះជាម្ចាស់ប្រោសប្រណី ប្រទានមកបង
ប្អូនជាមត៌ក ដើម្បីកុំឲ្យមានអ្វីមករារាំងការ
អធិស្ឋានរបស់បងប្អូនឡើយ។

## ទំនាក់ទំនងរវាងបងប្អូន

៨នៅទីបញ្ចប់ត្រូវមានចិត្តគំនិតតែមួយ និង
រួមសុខទុក្ខជាមួយគ្នា។ ត្រូវមានចិត្តស្រឡាញ់
គ្នាទៅវិញទៅមក ដូចបងប្អូនបង្កើត មានចិត្ត
អាណិតមេត្តា និងសុភាព។ ៩កុំប្រព្រឹត្តអំពើ
អាក្រក់តបនឹងអំពើអាក្រក់ កុំជេរប្រមាថតបនឹង
អ្នកដែលជេរប្រមាថបងប្អូន គឺត្រូវជូនពរគេវិញ
ដ្បិតព្រះជាម្ចាស់បានត្រាស់ហៅបងប្អូន ឲ្យ
ប្រព្រឹត្តដូច្នេះឯង ដើម្បីឲ្យបងប្អូនបានទទួល
ព្រះពររបស់ព្រះអង្គតាមព្រះបន្ទូលសន្យា[ន]។

១០ *«អ្នកណាស្រឡាញ់ជីវិត*
*និងចង់បានសុភមង្គល*

*អ្នកនោះត្រូវទប់មាត់កុំពោលពាក្យអាក្រក់*
*ព្រមទាំងទប់បបូរមាត់*
*កុំឲ្យនិយាយបោកបញ្ឆោត។*
១១ *អ្នកនោះត្រូវចៀសវាងកុំប្រព្រឹត្តអំពើអាក្រក់*
*ហើយត្រូវប្រព្រឹត្តអំពើល្អ*
*និងខិតខំស្វែងរកសេចក្ដីសុខសាន្ត*
១២ *ដ្បិតព្រះអម្ចាស់ទតមើលមកមនុស្សសុចរិត**
*ហើយទ្រង់ព្រះសណ្ដាប់ពាក្យទូលអង្វររបស់គេ*
*ប៉ុន្តែព្រះអង្គជំទាស់នឹងអស់អ្នកដែលប្រព្រឹត្ត*
*អំពើអាក្រក់»*[ខ]។
១៣ប្រសិនបើ បងប្អូនខ្នះខ្នែងប្រព្រឹត្តអំពើល្អ
តើនរណានឹងធ្វើបាបបងប្អូន? ១៤យ៉ាងណាមិ
ញ បើបងប្អូនរងទុក្ខវេទនាព្រោះតែសេចក្ដី
សុចរិត*នោះបងប្អូនមានសុភមង្គលហើយ។
សូមកុំភ័យខ្លាចមនុស្សលោកឡើយ ហើយក៏
មិនត្រូវតប់ប្រមល់ដែរ[គ] ១៥តែត្រូវទុកឲ្យព្រះគ្រី
ស្ត*ជាព្រះអម្ចាស់សម្ដែងព្រះបារមី ក្នុងចិត្ត
គំនិតរបស់បងប្អូនវិញ។ ត្រូវប្រុងប្រៀបខ្លួន
ឆ្លើយតទល់នឹងអស់អ្នកដែលសាកសួរ អំពី
សេចក្ដីសង្ឃឹមរបស់បងប្អូននោះជានិច្ច ១៦ប៉ុន្តែ
ត្រូវឆ្លើយទៅគេដោយទន់ភ្លន់ដោយគោរព និង
ដោយមានមនសិការល្អ ដើម្បីឲ្យអស់អ្នកដែល
ចង់មួលបង្កាច់កិរិយាល្អរបស់បងប្អូន ជាអ្នកជឿ
ព្រះគ្រីស្ត*ត្រង់ចំណុចណាមួយ បែរជាត្រូវ
ខ្មាសទៅវិញ។ ១៧សូវរងទុក្ខដោយប្រព្រឹត្តអំពើ
ល្អ ជាជាងប្រព្រឹត្តអំពើអាក្រក់ ប្រសិនបើព្រះជា
ម្ចាស់សព្វព្រះហឫទ័យយ៉ាងនេះ។

១៨សូម្បីតែព្រះគ្រីស្ត*ក៏ព្រះអង្គបានសោយ
ទិវង្គតម្ដងជាសូរេច ព្រោះតែបាបដែរ គឺព្រះដ៏
សុចរិត*បានសោយទិវង្គត ជាប្រយោជន៍ដល់
មនុស្សទុច្ចរិត ដើម្បីនាំបងប្អូនទៅថ្វាយព្រះជា
ម្ចាស់។ កាលព្រះអង្គមានឋានៈជាមនុស្ស ទ្រង់
ត្រូវគេធ្វើគុត តែព្រះជាម្ចាស់បានប្រោសព្រះ
អង្គឲ្យមានព្រះជន្មរស់ ដោយសារព្រះវិញ្ញាណវិ
ញ។ ១៩នៅពេលនោះ[ឃ] ព្រះអង្គបានយាងទៅ
ប្រកាសព្រះបន្ទូលដល់វិញ្ញាណក្ខន្ធ[ង] ដែលជាប់
ឃុំឃាំង ២០ជាវិញ្ញាណក្ខន្ធរបស់អ្នកបះបោរ
ប្រឆាំងនឹងព្រះជាម្ចាស់ កាលពីសម័យដើមក្នុង
ពេលដែលព្រះអង្គអត់ធ្មត់ នៅសម័យលោកណូ
អេសង់ទូកធំ។ មានមនុស្សមួយចំនួនតូចដែល
បានចូលទៅក្នុងទូក និងបានរួចជីវិតដោយសារ
ទឹក គឺមានតែប្រាំបីនាក់ប៉ុណ្ណោះ។២១នេះជា
និមិត្តរូបនៃពិធីជ្រមុជទឹក* ដែលសង្គ្រោះបង
ប្អូននាបច្ចុប្បន្នកាល តែពិធីជ្រមុជទឹក មិនមែន
ជាពិធីលាងជម្រះរូបកាយនោះទេ គឺជាការ
ថ្វាយជីវិតទាំងស្រុង ទៅព្រះជាម្ចាស់ដោយ
មនសិការល្អវិញ។ ពិធីជ្រមុជទឹកនេះសង្គ្រោះ
បងប្អូនដោយសារព្រះយេស៊ូគ្រីស្តមានព្រះជន្ម
រស់ឡើងវិញ ២២ព្រះអង្គបានយាងឡើងទៅ
ស្ថានបរមសុខ* គង់នៅខាងស្ដាំព្រះជាម្ចាស់
ហើយពួកទេវទូត* ព្រមទាំងវត្ថុស័ក្ដិសិទ្ធិនានា
ដែលមានអំណាច និងឫទ្ធានុភាពនានាចុះចូល
នឹងព្រះអង្គទាំងអស់។

## ការរស់នៅដោយមិនប្រព្រឹត្តអំពើបាប

១ហេតុនេះ បើព្រះគ្រីស្តបានរងទុក្ខលំបាក
៤កាលព្រះអង្គមានឋានៈជាមនុស្ស បងប្អូនត្រូវ
ប្រកាន់ចិត្តគំនិតដូចព្រះអង្គដែរ ដ្បិតអ្នកណាស៊ូ
ទ្រាំរងទុក្ខលំបាកខាងរូបកាយ អ្នកនោះលែង

ទាក់ទាមអ្វីនឹងបាប*ទៀតហើយ ២ដើម្បីឲ្យ
បានរស់ស្របតាមព្រះហឫទ័យរបស់ព្រះជា
ម្ចាស់ ក្នុងកំឡុងពេលនៃអាយុជីវិតដែលនៅ
សល់នេះ គឺមិនរស់នៅតាមចំណង់តណ្ហារបស់
មនុស្សទៀតទេ។ ៣ពីដើមបងប្អូនរស់នៅតាម
របៀប ដែលអស់អ្នកមិនស្គាល់ព្រះជាម្ចាស់[ម]
ចូលចិត្តនោះយូរពេកហើយ គឺបានប្រព្រឹត្តអំពើ
អបាយមុខលោភលន់ប្រមឹកស៊ីផឹកជ្រុល និង
ថ្វាយបង្គំព្រះក្លែងក្លាយនានា គួរឲ្យខ្ពើម។ ៤ពួក
គេងឿងឆ្ងល់ដោយឃើញបងប្អូនពុំចូលរួម
ជាមួយគេ ក្នុងការប្រព្រឹត្តអំពើថោកទាបហួស
ហេតុទាំងនោះទៀត ហើយគេក៏និយាយប្រមាថ
បងប្អូន។ ៥អ្នកទាំងនោះនឹងត្រូវឆ្លើយរៀបរាប់ពី
អំពើដែលខ្លួនប្រព្រឹត្ត នៅចំពោះព្រះភក្ត្រព្រះ
អង្គ ដែលប្រុងប្រៀបនឹងវិនិច្ឆ័យទោសទាំង
មនុស្សរស់ ទាំងមនុស្សស្លាប់។ ៦ហេតុនេះ សូ
ម្បីតែមនុស្សស្លាប់ក៏ព្រះអង្គបាននាំដំណឹងល្អ
ទៅឲ្យគេឮដែរ។ ដូច្នេះទោះបីពួកគេត្រូវទទួល
ការវិនិច្ឆ័យទោស តាមរបៀបមនុស្សលោកក្នុង
ពេលគេរស់នៅក្នុងលោកីយ៍នេះក៏ដោយ ក៏គេ
អាចមានជីវិតរស់ស្របតាមព្រះជាម្ចាស់
ដោយសារព្រះវិញ្ញាណដែរ[យ]។

## របៀបរស់នៅក្នុងក្រុមគ្រីស្ដបរិស័ទ

៧អ្វីៗទាំងអស់ ជិតរលាយសូន្យហើយហេតុ
នេះត្រូវគិតឲ្យវែងឆ្ងាយ និងភ្ញាក់ស្មារតីឡើង
ដើម្បីឲ្យអធិស្ឋាន*កើត។ ៨ជាបឋមត្រូវមាន
ចិត្តស្រឡាញ់គ្នាទៅវិញទៅមកជានិច្ច ដ្បិត
សេចក្ដីស្រឡាញ់ រមែងគ្របបាំងអំពើបាបដ៏
ច្រើនលើសលប់[រ]។ ៩ត្រូវចេះទទួលគ្នាទៅវិញ
ទៅមកដោយរាក់ទាក់ឥតរអ៊ូរទាំឡើយ។

១០បងប្អូនម្នាក់ៗ បានទទួលព្រះអំណោយ
ទានផ្សេងៗពីគ្នា ហើយដូច្នេះចូរយកព្រះ
អំណោយទានទាំងនេះ ទៅបម្រើអ្នកឯទៀតៗ
ឲ្យសមនឹងនាទីរបស់បងប្អូន ជាអ្នកចាត់ចែងដ៏
ល្អដែលចែកព្រះអំណោយទាន[ល]គ្រប់បែបយ៉ាង
របស់ព្រះជាម្ចាស់។ ១១បើអ្នកណានិយាយត្រូវ
និយាយ ឲ្យស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចា
ស់។ បើអ្នកណាបម្រើ ត្រូវបម្រើតាមកម្លាំង
ដែលព្រះជាម្ចាស់ប្រទានឲ្យ ដើម្បីលើកតម្កើង
សិរីរុងរឿងរបស់ព្រះជាម្ចាស់ ក្នុងគ្រប់កិច្ចការ
ទាំងអស់តាមរយៈព្រះយេស៊ូគ្រីស្ដ។ សូមលើក
តម្កើងសិរីរុងរឿង និងព្រះចេស្ដារបស់ព្រះអង្គ
អស់កល្បជាអង្វែងតរៀងទៅ! អាម៉ែន!

## ទុក្ខលំបាករបស់គ្រីស្ដបរិស័ទ

១២បងប្អូនជាទីស្រឡាញ់អើយ! ចំពោះទុក្ខ
លំបាកដ៏ខ្លាំង[វ] ដែលកើតមានដើម្បីលត់ដំបង
ប្អូននោះ សូមកុំងឿងឆ្ងល់ដោយគិតថាជា
ព្រឹត្តិការណ៍អ្វីមួយដ៏ចម្លែកឡើយ។ ១៣ផ្ទុយទៅ
វិញ ចូរមានចិត្តរីករាយឡើង ព្រោះបងប្អូនរង
ទុក្ខលំបាកផ្សេងៗ រួមជាមួយព្រះគ្រីស្ដ*។បង
ប្អូនមុខជាមានអំណរសប្បាយ យ៉ាងខ្លាំងនៅ
ពេលព្រះអង្គបង្ហាញ សិរីរុងរឿងរបស់ព្រះអង្គ។

១៤ប្រសិនបើ មានគេត្មះតិះដៀលបងប្អូន
ព្រោះតែព្រះនាមរបស់ព្រះគ្រីស្ដ* នោះបងប្អូន
មានសុភមង្គល*ហើយ ដ្បិតព្រះវិញ្ញាណប្រកប
ដោយសិរីរុងរឿង គឺព្រះវិញ្ញាណរបស់ព្រះជា
ម្ចាស់ស្ថិតនៅលើបងប្អូន។ ១៥ក្នុងចំណោមបង

ប្អូន សូមកុំឲ្យមាននរណាម្នាក់រងទុក្ខលំបាក
ព្រោះបានសម្លាប់គេលួចគេប្រព្រឹត្តអំពើអាក្រក់
ឬឡុកឡុំ ក្នុងរឿងរ៉ាវរបស់អ្នកដទៃឡើយ។
១៦ប៉ុន្តែបើបងប្អូនណារងទុក្ខលំបាក ក្នុងនាមជា
គ្រីស្តបរិស័ទកុំអៀនខ្មាសឲ្យសោះ ផ្ទុយទៅវិញ
បងប្អូននោះត្រូវតែលើកតម្កើងសិរីរុងរឿង ព្រះ
ជាម្ចាស់ ព្រោះតែនាមនេះ។

១៧ពេលកំណត់ ដែលព្រះជាម្ចាស់ចាប់ផ្ដើម
វិនិច្ឆ័យទោសមនុស្សលោកមកដល់ហើយ គឺ
ទ្រង់វិនិច្ឆ័យទោសប្រជារាស្ត្ររបស់ព្រះអង្គ មុន
គេ។ ប្រសិនបើព្រះអង្គចាប់ផ្ដើមវិនិច្ឆ័យទោស
ពីយើងទៅហើយ ចុះទម្រាំបើអស់អ្នកដែលពុំ
ព្រមជឿដំណឹងល្អរបស់ព្រះជាម្ចាស់វិញ តើនឹង
ធ្លាក់ទៅដល់កម្រិតណា!។ ១៨បើមនុស្ស
សុចរិតរួចជីវិតទាំងពិបាកយ៉ាងហ្នឹងទៅហើយ
ចុះទម្រាំបើមនុស្សទុច្ចរិតនិងមនុស្សបាបវិញ តើ
នឹងទៅជាយ៉ាងណា!។ ១៩ហេតុនេះអស់អ្នក
ដែលរងទុក្ខលំបាកស្របតាមព្រះហឫទ័យព្រះ
ជាម្ចាស់ត្រូវប្រព្រឹត្តអំពើល្អ ហើយផ្ញើជីវិតលើ
ព្រះអាទិករ* ដែលមានព្រះហឫទ័យស្មោះត្រ
ង់។

## ការកិច្ចរបស់អ្នកទទួលខុសត្រូវព្រះសហគមន៍

១ចំពោះព្រឹទ្ធាចារ្យ* ដែលនៅក្នុងចំណោម
៥បងប្អូនក្នុងនាមខ្ញុំជាព្រឹទ្ធាចារ្យដូចគ្នា ហើយ
ជាបន្ទាល់អំពីទុក្ខលំបាករបស់ព្រះគ្រីស្ត* និង
ជាអ្នករួមទទួលសិរីរុងរឿង ដែលនឹងត្រូវលេច
មក ខ្ញុំសូមដាស់តឿនថា៖ ២សូមមើលថែរក្សា
ហ្វូងចៀម[ស] ដែលព្រះជាម្ចាស់ផ្ញើទុកនឹងបងប្អូន
ដោយចិត្តស្មោះស្ម័គ្រ ស្របតាមព្រះហឫទ័យ
ព្រះជាម្ចាស់ គឺមិនមែនដោយទើសទ័ល ឬ
ដោយចង់បានកម្រៃអ្វីដែរ តែត្រូវមើលថែរក្សា
ដោយសុទ្ធចិត្ត។ ៣កុំប្រើអំណាចជិះជាន់អស់
អ្នក ដែលព្រះជាម្ចាស់ប្រទានមកឲ្យបងប្អូនថែ
រក្សានោះឡើយ គឺត្រូវធ្វើជាគំរូដល់ហ្វូងចៀមវិ
ញ។ ៤ពេលអ្នកគង្វាលដ៏ឧត្ដមយាងមកដល់
បងប្អូននឹងទទួលមកុដ ដ៏រុងរឿង ដែលមិនចេះ
អាប់រស្មី។

## ការកិច្ចរបស់អ្នកជឿ

រីឯពួកយុវជនវិញ ក៏ដូច្នោះដែរ ត្រូវគោរពចុះ
៥ចូលនឹងព្រឹទ្ធាចារ្យ*។ ចូរទាក់ទងគ្នាទៅវិញ
ទៅមកដោយសុភាពរាបសា ដ្បិត«ព្រះជាម្ចាស់
ប្រឆាំងនឹងអស់អ្នក ដែលអួតខ្លួនតែទ្រង់ប្រណី
សន្ដោសអស់អ្នក ដែលដាក់ខ្លួនវិញ»[ហ]។
៦ដូច្នេះ ត្រូវដាក់ខ្លួននៅក្រោមព្រះហស្ដដ៏
មានឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដើម្បីឲ្យព្រះ
អង្គលើកតម្កើងបងប្អូន នៅពេលដែលព្រះអង្គ
បានកំណត់ទុក។ ៧ចូរផ្ទេរទុក្ខកង្វល់ទាំងប៉ុន្មាន
របស់បងប្អូនទៅព្រះអង្គទៅ ដ្បិតទ្រង់យកព្រះ
ហឫទ័យទុកដាក់នឹងបងប្អូន។

៨ត្រូវភ្ញាក់ខ្លួនហើយប្រុងស្មារតីជានិច្ច! ដ្បិត
មារ*ជាសត្រូវនឹងបងប្អូន កំពុងតែក្រវែលជុំវិញ
បងប្អូនដូចសឹង្ហក្រវែលទាំងគ្រហឹមរកត្របាក់ស៊ី
អ្នកណាម្នាក់។ ៩ចូរប្រឆាំងនឹងវាហើយមាន
ជំនឿមាំមួនឡើង ដោយដឹងថា បងប្អូនរួមជំនឿ
ឯទៀតៗ នៅក្នុងសកលលោកទាំងមូលក៏ត្រូវ

រងទុក្ខលំបាកដូចបងប្អូនដែរ។

១០បន្ទាប់ពី បងប្អូនបានរងទុក្ខលំបាកមួយរយៈពេលខ្លីនេះរួចហើយ ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យ ប្រណីសន្ដោស គ្រប់យ៉ាងដែលបានត្រាស់ហៅបងប្អូន ឲ្យទទួលសិរីរុងរឿងដ៏ស្ថិតស្ថេរអស់កល្បជានិច្ច រួមជាមួយព្រះគ្រីស្ដ* ព្រះអង្គនឹងលើកបងប្អូនឲ្យមានជំហរឡើងវិញប្រទានឲ្យបងប្អូនបានរឹងប៉ឹងមាន កម្លាំង និងឲ្យបងប្អូនបានមាំមួនឥតរង្គើឡើយ។ ១១សូមឲ្យព្រះអង្គបាន ប្រកបដោយព្រះចេស្ដា សូមលើកតម្កើងព្រះចេស្ដារបស់ព្រះអង្គ អស់កល្បជាអង្វែងតរៀងទៅ! អាម៉ែន!

## អវសានកថា

១២ខ្ញុំសរសេរលិខិតដ៏ខ្លី ផ្ញើមកជូនបងប្អូននេះដោយមានលោកស៊ីលវ៉ាន[ឡ] ជាអ្នកស្មោះត្រង់បានជួយ ដើម្បីលើកទឹកចិត្តបងប្អូន និងបញ្ជាក់ប្រាប់បងប្អូនថា បងប្អូនពិតជាស្ថិតនៅជាប់នឹងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់មែន[អ]។

១៣ព្រះសហគមន៍*នៅក្រុងបាប៊ីឡូន សូមជម្រាបសួរមកបងប្អូន ហើយលោកម៉ាកុសជាកូនរបស់ខ្ញុំ សូមជម្រាបសួរមកបងប្អូនដែរ។ ១៤ចូរជម្រាបសួរគ្នាទៅវិញទៅមក ដោយស្និទ្ធស្នាល[ក]។

សូមឲ្យបងប្អូនទាំងអស់ ដែលរួមរស់នឹងព្រះគ្រីស្ដបានប្រកបដោយសេចក្ដីសុខសាន្ត។

*ក. «ព្រះអង្គប្រោះព្រះលោហិតរបស់ព្រះអង្គលើបងប្អូន»* មានន័យ*ថា ព្រះអង្គប្រទានឲ្យយើងចូលរួមក្នុងសម្ពន្ធមេត្រីថ្មីដោយសារព្រះលោហិតរបស់ព្រះអង្គ។•ខ.«*មត៌ក*» ក្នុងសម្ពន្ធមេត្រីចាស់សំដៅទៅលើទឹកដីដែលព្រះជាម្ចាស់សន្យាប្រទានឲ្យជនជាតិអ៊ីស្រាអែល រីឯក្នុងសម្ពន្ធមេត្រីថ្មីមត៌កសំដៅទៅលើព្រះរាជ្យ* ដែលព្រះជាម្ចាស់ប្រទានឲ្យពួកអ្នកជឿ។•គ.ឬល្បួងល។*

*ឃ. ពាក្យដើម«កាលបងប្អូននៅលិ្ងតលង់» ។ • ង. លេវីវិន័យ ១៩.២។*

*ច. អេសាយ ៤០.៦–៨។•ឆ.ទំនុកតម្កើង៣៤.៩។•ជ.អេសាយ ២៨.១៦។•ឈ.ទំនុកតម្កើង១១៨.២២។•ញ.អេសាយ ៨.១៤។•ដ.សេរីភាព(និក្ខមនំ) ១៩.៥,៦; អេសាយ៤៣. ២០,២១។*

*ឋ.ដកស្រង់ពីហូសេស្ដីអំពីអត្ថន័យនៃឈ្មោះកូនរបស់ព្យាការីហូសេ (ហូសេ១.៦,៩;២.១,២៥)។•ឌ.យើងអាចបកប្រែថាអាណិកជនក៏បាន។•ឍ.ពាក្យដើម:សេចក្ដីប៉ងប្រាថ្នាក្នុងនិស្ស័យជាមនុស្ស។•ណ.ពាក្យដើម« យាងមកសួរសុខទុក្ខ» មានន័យថាព្រះជាម្ចាស់យាងមកសង្គ្រោះឬវិនិច្ឆ័យទោសមនុស្សបាប។•ត. ឬ«បងប្អូននឹងបានគាប់ព្រះហឫទ័យព្រះជាម្ចាស់ពុំខាន» ។•ថ. អេសាយ ៥៣.៩។*

*ទ.ឃ្លាដើម«ឲ្យយើងស្លាប់ខាងអំពើបាបរបស់យើង» ដែលមានន័យថាយើងរំងាប់អំពើបាបឬលែងប្រព្រឹត្តអំពើបាបទៀត។•ធ. សូមអាន អេសាយ ៥៣.៥។*

*ន.ឃ្លាដើម«‌ៈ ឲ្យបងប្អូនបានទទួលព្រះពររបស់ព្រះអង្គទុកជាមត៌ក» ។ពាក្យមត៌កនេះសំដៅទៅលើព្រះរាជ្យរបស់ព្រះជាម្ចាស់ឬសម្បត្តិសួគ៌ដែលនៅស្ថិតស្ថេរឥតទីបញ្ចប់។ប.ទំនុកតម្កើង ៣៤.១៣–១៧។•ផ.អេសាយ៨.១២–១៣។•ព. «នៅពេលនោះ» ឬ«ដោយសារព្រះវិញ្ញាណហ្នឹងហើយ» ។•ភ. ពាក្យ«វិញ្ញាណក្ខ័ន្ធ» នេះ យើងអាចបកប្រែថា«ព្រលឹង» ក៏បាន។*

*ម.«អ្នកមិនស្គាល់ព្រះជាម្ចាស់»:ពាក្យដើម«សាសន៍ដទៃ» ។•យ.យើងអាចបកស្រាយថា:គ្រីស្ដបរិស័ទបានស្លាប់ដូចគេដូចឯងមែនប៉ុន្តែគេមានជីវិតរស់ជាមួយព្រះជាម្ចាស់ព្រោះគេបានជឿ*

ដំណឹងល្អ។•រ. សុភាសិត១០.១២។•ល. ឬព្រះហឫទ័យប្រណីសន្តោស។ •វ.ពាក្យដើម«ខ្ទះភ្លើង» ដែលជារូបភាពនៃការសំរាំងមាស ដោយដុតនឹងភ្លើង(១.៧)។

ស. ហ្វូងចៀមរបស់ព្រះជាម្ចាស់ គឺព្រះសហគមន៍នៅតាមកន្លែងនីមួយៗ។ • ហ. សុភាសិត៣.៣៤។

ឡ.ស៊ីឈាំនឬស៊ីឡាសប្រហែលជាមនុស្សតែមួយ។•អ.យើងអាចបកស្រាយបានពីរយ៉ាង: ទីមួយ«សេចក្ដីដែលមានសរសេរនៅក្នុងសំបុត្រនេះហើយដែលបងប្អូនជឿពិតជាបង្ហាញព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់មែន» ឬ«ការរស់នៅទាំងវេទនារបស់បងប្អូនពិតជាស្របតាមព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់មែន» ។•ក.«ជម្រាបសួរគ្នាដោយស្និទ្ធស្នាល»: សូមអានសេចក្ដីពន្យល់នៅ១កូរិនថូស១៦.២០។

# ពាក្យលំនាំ

យើងពុំដឹងថា លោកសិលាបានតែងលិខិតទីពីរនេះនៅពេលណាទេ។ អ្នកស្រាវជ្រាវខ្លះសន្និដ្ឋានថា មានគ្រីស្តបរិស័ទម្នាក់បានតែងលិខិតនេះប្រហែលជានៅចុងសតវត្សទីមួយ ឬដើមសតវត្សទីពីរ។

## គោលបំណង

លិខិតទីពីរនេះមានបំណងចង់ដាស់តឿនគ្រីស្តបរិស័ទ កុំឲ្យបណ្តោយខ្លួនទៅតាមគ្រូអាចារ្យក្លែងក្លាយដែលប្រៀនប្រដៅលទ្ធិផ្សេងៗខុសពីការប្រៀនប្រដៅរបស់ក្រុមគ្រីស្តទូត។ ក្នុងលិខិតនេះមានបញ្ជាក់យ៉ាងច្បាស់ អំពីដើមកំណើតនៃព្រះគម្ពីរទាំងមូល គឺព្រះវិញ្ញាណនៃព្រះជាម្ចាស់បានណែនាំអ្នកតែងឲ្យសរសេរ ហេតុនេះហើយបានជាគ្រីស្តបរិស័ទត្រូវតែយល់ព្រះគម្ពីរតាមព្រះវិញ្ញាណបំភ្លឺនិងតាមការបង្រៀនរបស់ព្រះសហគមន៍។

នៅចំពូកទីបី ជាសេចក្តីឆ្លើយតបទៅអស់អ្នកដែលមាក់ងាយគ្រីស្តបរិស័ទ ព្រោះគេទន្ទឹងរង់ចាំព្រះអម្ចាស់យាងមកវិញ។ លោកសិលាតបថា ហេតុដែលព្រះយេស៊ូពុំបានយាងមកវិញឆាប់ៗនោះ មកពីព្រះអង្គមានព្រះហឫទ័យអត់ធ្មត់ចំពោះមនុស្សមានបាប ព្រះអង្គទុកឱកាសឲ្យមនុស្សជាច្រើនទៀតប្រែចិត្តគំនិត ដើម្បីទទួលការសង្គ្រោះពីព្រះជាម្ចាស់។

# លិខិតទីពីររបស់លោកសិលា

## សេចក្ដីផ្ដើម

១ខ្ញុំ ស៊ីម៉ូនសិលា ជាអ្នកបម្រើ និងជាគ្រីស្ដ
១ទូត*របស់ព្រះយេស៊ូគ្រីស្ដ* សូមជម្រាបមក
បងប្អូនដែលបានទទួលជំនឿ ដោយសារ
សេចក្ដីសុចរិត*របស់ព្រះយេស៊ូគ្រីស្ដ ជាព្រះ
ជាម្ចាស់ និងជាព្រះសង្គ្រោះរបស់យើង។ជំនឿ
របស់បងប្អូនក៏មានតម្លៃ ដូចជំនឿរបស់យើងដែ
រ។ ២សូមព្រះជាម្ចាស់ប្រណីសន្ដោស និង
ប្រទានសេចក្ដីសុខសាន្ដ មកបងប្អូនឲ្យបានបរិ
បូណ៌ ដោយបងប្អូនបានស្គាល់ព្រះអង្គ និង
ស្គាល់ព្រះយេស៊ូ ជាព្រះអម្ចាស់របស់យើង
យ៉ាងច្បាស់។

## ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្ដបរិស័ទ

៣ឫទ្ធានុភាពរបស់ ព្រះជាម្ចាស់ប្រទានឲ្យ
យើងមានអ្វីៗទាំងអស់សម្រាប់ជីវិតរស់នៅ និង
សម្រាប់គោរពប្រណិប័តន៍ព្រះអង្គ។ ឫទ្ធានុ
ភាពនោះនាំយើងឲ្យស្គាល់ព្រះអង្គ ដែលបាន
ត្រាស់ហៅយើង ដោយសារសិរីរុងរឿងរបស់
ព្រះអង្គផ្ទាល់ និងដោយសារព្រះបារមីរបស់ព្រះ
អង្គ។ ៤ដោយសារសិរីរុងរឿងនិងព្រះបារមីនេះ
ព្រះអង្គបានប្រទានព្រះអំណោយទានដ៏មាន
តម្លៃវិសេសបំផុតមកយើង តាមព្រះបន្ទូល
សន្យា ដើម្បីឲ្យបងប្អូនមានលក្ខណៈជាព្រះជា
ម្ចាស់ រួមជាមួយព្រះអង្គ[ក] ដោយបោះបង់ចោល
សេចក្ដីវិលួយ ដែលមកពីការលោភលន់ក្នុង
លោកីយ៍។ ៥ហេតុនេះបងប្អូនត្រូវខ្នះខ្នែងឲ្យ
អស់ពីសមត្ថភាព បន្ថែមកិរិយាល្អឥតខ្ចោះ[ខ]ពី
លើជំនឿ បន្ថែមការស្គាល់ព្រះអង្គពីលើកិរិយា
ល្អ ៦បន្ថែមការចេះទប់ចិត្តពីលើការស្គាល់ព្រះ
អង្គ បន្ថែមការព្យាយាមតស៊ូពីលើការចេះទប់
ចិត្ត បន្ថែមការគោរពប្រណិប័តន៍ព្រះជាម្ចាស់ពី
លើការព្យាយាមតស៊ូ ៧បន្ថែមភាតរភាពពីលើ
ការគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងបន្ថែម
សេចក្ដីស្រឡាញ់ ពីលើភាតរភាព។ ៨ប្រសិន
បើ បងប្អូនមានគុណសម្បត្តិទាំងនេះពេញបរិបូ
ណ៌ក្នុងខ្លួន ហើយគុណសម្បត្តិទាំងនេះមុខជា
នាំបងប្អូនឲ្យមានសកម្មភាព និងបង្កើតផល
ដើម្បីបានស្គាល់ព្រះយេស៊ូគ្រីស្ដ*ជាព្រះ
អម្ចាស់របស់យើងយ៉ាងច្បាស់។ ៩ផ្ទុយទៅវិញ
បើអ្នកណាគ្មានគុណសម្បត្តិទាំងនេះទេអ្នក
នោះជាមនុស្សខ្វាក់ មើលឃើញមិនបានវែង
ឆ្ងាយ គេភ្លេចថាព្រះជាម្ចាស់បានលាងជម្រះគេ
ពីអំពើបាប ដែលគេប្រព្រឹត្ដពីអតីតកាល។
១០ហេតុនេះបងប្អូនអើយ ចូរខំប្រឹងយកចិត្តទុក
ដាក់ ធ្វើឲ្យការត្រាស់ហៅនិងការជ្រើសរើស
របស់ព្រះជាម្ចាស់បានកាន់តែខ្ជាប់ខ្ជួនឡើងថែម
ទៀត។ ធ្វើយ៉ាងនេះបងប្អូនមុខជាមិនជំពប់
ដួលឡើយ។ ១១ដូច្នេះបងប្អូននឹងទទួលសិទ្ធិដ៏ធំ
ទូលំទូលាយអាចចូលទៅក្នុងព្រះរាជ្យ* ដែល
នៅស្ថិតស្ថេរអស់កល្បជានិច្ចគឺ ព្រះរាជ្យរបស់
ព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់ និងជាព្រះស
ង្គ្រោះរបស់យើង។

១២ហេតុនេះ ខ្ញុំនឹងរំឭកដាស់តឿនបងប្អូន
អំពីសេចក្ដីទាំងនោះជានិច្ច ទោះបីបងប្អូនបាន
ដឹង និងនៅតែកាន់តាមសេចក្ដីពិតដែលបងប្អូន

បានទទួល យ៉ាងខ្ជាប់ខ្ជួនហើយក៏ដោយ។
[១៣]ដរាបណា ខ្ញុំនៅមានជីវិតរស់ក្នុងលោកីយ៍
នេះនៅឡើយ ខ្ញុំយល់ឃើញថា ត្រូវតែរំឭកបង
ប្អូនឲ្យភ្ញាក់ស្មារតី។ [១៤]ខ្ញុំដឹងថា ខ្ញុំនឹងត្រូវលា
ចាកលោកនេះក្នុងពេលឆាប់ៗ ខាងមុខដូចព្រះ
យេស៊ូគ្រីស្ដ ជាព្រះអម្ចាស់នៃយើងបានសម្ដែង
ឲ្យខ្ញុំដឹងស្រាប់។ [១៥]ប៉ុន្តែ ខ្ញុំនឹងខ្នះខ្នែងធ្វើយ៉ាង
ណា ឲ្យបងប្អូនអាចនឹកឃើញសេចក្ដីទាំងនោះ
គ្រប់កាលៈទេសៈទាំងអស់ ក្រោយពេលខ្ញុំចាក
លោកនេះទៅ។

## បន្ទាល់អំពីសិរីរុងរឿងរបស់ព្រះយេស៊ូ

[១៦]យើងពុំបានយករឿងប្រឌិតផ្សេងៗ មក
ណែនាំបងប្អូន ឲ្យស្គាល់ឫទ្ធានុភាពរបស់ព្រះ
យេស៊ូគ្រីស្ដ* ជាព្រះអម្ចាស់នៃយើង និងឲ្យដឹង
ថា ព្រះអង្គត្រូវយាងមកនោះឡើយ គឺយើង
បានឃើញភាពថ្កុំថ្កើងរុងរឿង របស់ព្រះអង្គ
ផ្ទាល់នឹងភ្នែកតែម្ដង [១៧]ដ្បិតព្រះអង្គបានទទួល
កិត្តិនាម និងសិរីរុងរឿងពីព្រះជាម្ចាស់ជាព្រះ
បិតាមកនៅពេលដែលមានព្រះសូរសៀងលាន់
ឮចេញពីសិរីរុងរឿងដ៏ឧត្ដុង្គឧត្ដមមកកាន់ព្រះ
អង្គថា៖ "នេះជាព្រះបុត្រាដ៏ជាទីស្រឡាញ់
របស់យើងយើងគាប់ចិត្តនឹងព្រះអង្គណាស់!"។
[១៨]យើងបានឮព្រះសូរសៀងនេះ ពីលើមេឃមក
កាលយើងនៅជាមួយព្រះអង្គនៅលើភ្នំដ៏វិសុទ្ធ[គ]
[១៩]យើងក៏មានពាក្យព្យាការី* បានថ្លែងទុកមក
ផងដែរ ដែលជាគោលមួយដ៏មាំមួន។ បើបង
ប្អូនផ្ចង់ចិត្តទៅកាន់ពាក្យនេះ ពិតជាត្រឹមត្រូវ
ហើយ ព្រោះពាក្យនេះប្រៀបបាននឹងចង្កៀង
ដែលបំភ្លឺក្នុងទីងងឹតរហូតដល់ថ្ងៃរះ និងរហូត
ដល់ផ្កាយព្រឹករះឡើងក្នុងចិត្តបងប្អូន។ [២០]ជា
បឋម សូមបងប្អូនជ្រាបថាគ្មាននរណាម្នាក់អាច
បកស្រាយពាក្យរបស់ព្យាការី ដែលមានចែង
ទុកមកក្នុងគម្ពីរ តាមគំនិតរបស់ខ្លួនបានឡើយ
[២១]ដ្បិត ព្រះបន្ទូលដែលព្យាការីបានថ្លែងទុក
មកនោះ មិនមែនចេញពីបំណងចិត្តរបស់
មនុស្សទេគឺព្រះវិញ្ញាណដ៏វិសុទ្ធវិញឯណោះ
ដែលជំរុញចិត្តលោកទាំងនោះឲ្យថ្លែងព្រះ
បន្ទូល ក្នុងព្រះនាមព្រះជាម្ចាស់។

## អំពីគ្រូក្លែងក្លាយ

[១]កាលពីសម័យដើម មានព្យាការី*ក្លែងក្លាយ
២ស្ថិតនៅក្នុងចំណោមប្រជារាស្ត្រ។ ក្នុង
ចំណោមបងប្អូនក៏ដូច្នោះដែរ គឺនឹងមានគ្រូក្លែង
ក្លាយ មកសិកសៀតបញ្ចូលលទ្ធិខុស ដែល
បណ្ដាលឲ្យវិនាស គេបដិសេធពុំព្រមទទួល
ស្គាល់ព្រះអម្ចាស់ដែលបានលោះគេ ឲ្យរួចពី
បាបនោះទេ គេមុខជាត្រូវវិនាសអន្តរាយយ៉ាង
ទាន់ហន់មិនខាន។ [២]មនុស្សជាច្រើននឹងដើរ
តាមពួកគេ ទៅប្រព្រឹត្តអំពើអបាយមុខ ហើយ
មនុស្សម្នា នឹងប្រមាថមាគ៌ានៃសេចក្ដីពិត ព្រោះ
តែអ្នកទាំងនោះ។ [៣]ពួកគេនឹងបោកប្រាសបង
ប្អូនចង់បានប្រាក់ ដោយពោលពាក្យបញ្ឆោត
ប៉ុន្តែ ព្រះអង្គបានកាត់ទោសពួកគេ តាំងពីយូរ
យារណាស់មកហើយ ហើយព្រះអង្គឥត
ប្រហែសនឹងបំផ្លាញគេឡើយ[ឃ] [៤]ដ្បិតព្រះជា
ម្ចាស់ពុំបានយោគយល់ ដល់ពួកទេវទូត*
ដែលប្រព្រឹត្តអំពើបាបទេ ទ្រង់បានរុញពួកគេ
ទម្លាក់ទៅក្នុងនរកអវិចីដែលងងឹតសូន្យ ហើយ
គេជាប់ឃុំឃាំងនៅទីនោះ រង់ចាំពេលព្រះអង្គ

វិនិច្ឆ័យទោស។ ៥ព្រះអង្គក៏ពុំបានយោគយល់
ដល់ពិភពលោកនាបុរាណកាលដែរ គឺព្រះអង្គ
បានធ្វើឲ្យទឹកជន់លិចពិភពលោក ដ៏ទុច្ចរិត
នោះ។ព្រះអង្គទុកជីវិតមនុស្ស តែប្រាំបីនាក់
ប៉ុណ្ណោះឲ្យនៅរស់គិតទាំងលោកណូអេ ជាអ្នក
ប្រកាសសេចក្ដីសុចរិត*នោះផង។ ៦ព្រះអង្គ
បានដាក់ទោសក្រុងសូដុម និងក្រុងកូម៉ូរ៉ាឲ្យ
រលាយទៅជាផេះ ទុកជាការព្រមានដល់មនុស្ស
ទុច្ចរិតទៅថ្ងៃក្រោយ។ ៧ព្រះអង្គបានដោះលែង
តែលោកឡុតជាមនុស្សសុចរិត* ព្រោះគាត់
ព្រួយចិត្តដោយឃើញមនុស្សអាក្រក់នៅជំនាន់
នោះ វក់វីនឹងកាមគុណដ៏ថោកទាប។ ៨រៀង
រាល់ថ្ងៃលោកឡុតជាមនុស្សសុចរិត ដែលរស់
នៅកណ្ដាល ចំណោមមនុស្សអាក្រក់ទាំងនោះ
បានក្រំគ្រាក្នុងចិត្តដ៏សុចរិតរបស់គាត់ ព្រោះ
ឃើញហើយឮនូវអំពើទុច្ចរិតទាំងប៉ុន្មាន របស់
ពួកគេ។៩យ៉ាងនេះហើយ ដែលព្រះអម្ចាស់អាច
ដោះលែងអស់អ្នកគោរពប្រណិប័តន៍ព្រះអង្គ
ឲ្យរួចពីទុក្ខលំបាក[ង] តែព្រះអង្គទុកមនុស្ស
ទុច្ចរិតសម្រាប់ដាក់ទណ្ឌកម្ម នៅថ្ងៃដែលព្រះ
អង្គនឹងវិនិច្ឆ័យទោសមនុស្សលោក ១០ជា
ពិសេសព្រះអង្គដាក់ទណ្ឌកម្មអស់អ្នក ដែល
ប្រព្រឹត្តអំពើថោកទាប បំពេញតាមតណ្ហារបស់
លោកីយ៍ហើយមាក់ងាយ អំណាចរបស់ព្រះជា
ម្ចាស់។ គ្រូក្លែងក្លាយទាំងនោះវាយឫកខ្ពស់
ព្រហើនក្អេងក្អាង មិនញញើតនឹងជេរប្រមាថ
ពួកទេវតា[ច]ដែលប្រកបដោយសិរីរុងរឿងឡើ
យ។ ១១សូម្បីតែទេវទូត*ដែលមានកម្លាំង និង
ឫទ្ធានុភាពខ្លាំងជាងអ្នកទាំងនោះ ក៏ពុំដែល
ចោទប្រកាន់ប្រមាថទេវតានៅមុខព្រះជាម្ចាស់
ដែរ។ ១២រីឯអ្នកទាំងនោះវិញ ពួកគេប្រៀបបាន
នឹងសត្វតិរច្ឆានដែលកើតមកសម្រាប់តែជាប់
អន្ទាក់ និងត្រូវវិនាសអន្តរាយ ពួកគេនាំគ្នាជេរ
ប្រមាថអ្វីៗដែលគេពុំស្គាល់។ ពួកគេមុខជាត្រូវ
វិនាសសូន្យទៅដូចសត្វតិរច្ឆានដែរ។ ១៣អ្នក
ប្រព្រឹត្តអំពើទុច្ចរិត នឹងទទួលផលពីអំពើទុច្ចរិត
ដែលខ្លួនបានប្រព្រឹត្ត។ អ្នកទាំងនោះត្រេក
ត្រអាលនឹងការស្រើបស្រាលរបស់ខ្លួន ទាំងថ្ងៃ
ពួកគេជាមនុស្សមានចិត្តកខ្វក់ថោកទាប ហើយ
នៅពេលបរិភោគអាហាររួមជាមួយបងប្អូន គេ
សប្បាយចិត្ត ចំពោះការបោកប្រាស់របស់ខ្លួន
បែបនេះណាស់។ ១៤គេគិតតែពីរំពៃមើលស្រីៗ
ដោយចិត្តស្រើបស្រាល និងប្រព្រឹត្តអំពើបាប
មិនចេះស្កប់ឡើយ។ ពួកគេតែងទាក់ទាញចិត្ត
អស់អ្នកដែលមានជំនឿទន់ខ្សោយ ហើយពួក
គេពូកែខាងលោភលន់ចង់បានប្រាក់។ អ្នកទាំង
នោះសុទ្ធតែជាមនុស្សត្រូវបណ្ដាសា!។ ១៥ពួក
គេបានបោះបង់មាគ៌ាត្រឹមត្រូវចោល ងាកទៅ
ដើរតាមផ្លូវលោកបាឡាម ជាកូនរបស់លោកបូ
ស៊័រនិងជាអ្នកស្រឡាញ់ប្រាក់ ដែលគេជួលឲ្យ
ប្រព្រឹត្តអំពើទុច្ចរិត[ឆ]។ ១៦ប៉ុន្តែ ព្យាការី*នេះបាន
ទទួលការស្ដីប្រដៅ ព្រោះគាត់ប្រព្រឹត្តល្មើសវិ
ន័យ* គឺសត្វពាហនៈដែលមិនចេះនិយាយ បែរ
ជានិយាយភាសាមនុស្ស ឃាត់គាត់កុំឲ្យប្រព្រឹត្ត
អំពើលេលាយ៉ាងនោះឡើយ។

១៧អ្នកទាំងនោះ ប្រៀបបាននឹងប្រភពទឹក
ហួតហែង ឬពពកដែលត្រូវខ្យល់ព្យុះផាត់គេនឹង
ត្រូវធ្លាក់ទៅក្នុងទីងងឹតសូន្យសុង ជាមិនខាន។
១៨គេព្រោកប្រាជ្ញអំពីរឿងសម្បើមអស្ចារ្យ តែ
គ្មានខ្លឹមសារអ្វីសោះ ហើយយកតណ្ហាលោភ

លន់តាមលោកីយ៍ មកទាក់ទាញអស់អ្នកដែល
ទើបនឹងរួចពីចំណោមពួកវង្វេង។ ១៩ពួកគេ
សន្យាថានឹងផ្ដល់សេរីភាពឲ្យអ្នកទាំងនោះ តែ
ខ្លួនឯងផ្ទាល់ជាខ្ញុំកញ្ជះនៃសេចក្ដីអន្តរាយ[ជ]ដ្បិត
ម្នាក់ៗជាខ្ញុំកញ្ជះនៃអ្វីៗ ដែលមានអំណាចលើ
ខ្លួន។

២០ប្រសិនបើ អ្នកណាបានលះបង់អំពើ
សៅហ្មងនៃលោកីយ៍ ដោយបានស្គាល់ព្រះ
យេស៊ូគ្រីស្ដ*ជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះ
យ៉ាងច្បាស់ហើយ តែបែរជាបណ្ដោយឲ្យអំពើ
សៅហ្មងនេះ មានអំណាចរួបរឹត និងដឹកនាំសា
ជាថ្មី ជីវិតរបស់អ្នកនោះនឹងក្លាយទៅជាអាក្រក់
ជាងមុនទៅទៀត។ ២១សូវកុំឲ្យអ្នកនោះស្គាល់
មាគ៌ាសុចរិតជាជាងឲ្យស្គាល់ ហើយបែរជាងាក
ចេញពីវិន័យរបស់ព្រះជាម្ចាស់ ដែលខ្លួនបានទ
ទួល។ ២២ហេតុការណ៍ដែលកើតមានដល់គេ
នេះ សឲ្យឃើញថាសេចក្ដីដែលសុភាសិតចែង
ទុកមកនោះ ពិតជាត្រឹមត្រូវមែន គឺ«ឆ្កែរមែង
តែងតែវិលទៅរកកម្អួតរបស់វាវិញ[ឈ] ជ្រូកដែល
ទើបនឹងលាងស្អាត ក៏រមែងតែងតែវិលទៅ
ននៀលភក់វិញដែរ»។

## អំពីព្រះអម្ចាស់យាងវិលត្រឡប់មកវិញ

១បងប្អូនជាទីស្រឡាញ់អើយ នេះជាសំបុត្រ
ទីពីរ ដែលខ្ញុំសរសេរផ្ញើមកជូនបងប្អូន។
សេចក្ដីក្នុងសំបុត្រទាំងពីរនេះ ខ្ញុំបានរំឭក
ដាស់តឿនបងប្អូន ឲ្យមានចិត្តគំនិតត្រឹមត្រូវ[ញ]
ជានិច្ច។ ២សូមបងប្អូនកុំភ្លេចសេចក្ដីដែលអស់
លោកព្យាការី*ដ៏វិសុទ្ធ*បានថ្លែងទុកមក និងវិ
ន័យដែលព្រះអម្ចាស់ ជាព្រះសង្គ្រោះ បាន
បង្រៀន តាមរយៈគ្រីស្ដទូតនានារបស់បងប្អូន។
៣ជាបឋមសូមជ្រាបថា នៅគ្រាចុងក្រោយបំផុត
នឹងមានពួកអ្នកដែលរស់នៅតាមចិត្តលោភលន់
របស់ខ្លួន ហើយចំអកឡកឡឺយដាក់បងប្អូន
៤គេនឹងពោលថា «បើព្រះអង្គសន្យាថាយាង
មកមែននោះ តើឥឡូវទ្រង់នៅឯណា? តាំងពី
បុព្វបុរស*របស់យើងស្លាប់អស់ទៅ គ្មានអ្វី
ផ្លាស់ប្ដូរទេ គឺនៅតែដដែលដូចកាលពីព្រះអង្គ
បង្កើតពិភពលោក!»។ ៥គេនិយាយដូច្នេះមកពី
គេធ្វើជាភ្លេចថា កាលពីបុរាណផ្ទៃមេឃ និង
ផែនដីកកើតចេញពីទឹក ហើយផ្សំឡើងពីធាតុ
ទឹក ដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់។
៦បន្ទាប់មក ដោយទឹកដដែលពិភពលោកបាន
លិចលង់ នៅគ្រាទឹកជំនន់ធំ។ ៧មួយវិញទៀត
ព្រះបន្ទូលដដែលនេះបានថ្លែងថាផ្ទៃមេឃ និង
ផែនដីនាបច្ចុប្បន្នកាលនឹងត្រូវបម្រុងទុកឲ្យភ្លើង
ឆេះរំលាយ នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យ
ទោសមនុស្សទុច្ចរិត ឲ្យវិនាសអន្តរាយ។

៨បងប្អូនជាទីស្រឡាញ់អើយ សូមបងប្អូនកុំ
ភ្លេចចំណុចមួយនេះថា នៅចំពោះព្រះភ័ក្ត្រព្រះ
អម្ចាស់មួយថ្ងៃ ប្រៀបបាននឹងមួយពាន់ឆ្នាំ
ហើយមួយពាន់ឆ្នាំ ក៏ប្រៀបបាននឹងមួយថ្ងៃ[ដ]
ដូច្នោះដែរ។ ព្រះអម្ចាស់នឹងយាងមកតាមព្រះ
បន្ទូលសន្យារបស់ព្រះអង្គ ឥតបង្អែបង្អង់ ដូច
អ្នកខ្លះនឹកស្មាននោះឡើយ។ ព្រះអង្គសម្ដែង
ព្រះហឫទ័យអត់ធ្មត់ចំពោះបងប្អូនព្រោះទ្រង់
មិនសព្វព្រះហឫទ័យ ឲ្យនរណាម្នាក់ត្រូវវិនាស
ទេ គឺទ្រង់សព្វព្រះហឫទ័យឲ្យមនុស្សលោក

គ្រប់ៗរូប កែប្រែចិត្តគំនិតវិញ។ ១០ថ្ងៃដែលព្រះ
អម្ចាស់យាងមក ប្រៀបបានទៅនឹងពេលចោរ
ចូលលួចដូច្នោះដែរ។ នៅគ្រានោះផ្ទៃមេឃនឹង
រលាយសូន្យទៅ ដោយសន្ធឹកខ្ទរខ្ទារធាតុនានា
នឹងឆេះរលាយសូន្យអស់ទៅ ហើយព្រះជា
ម្ចាស់នឹងវិនិច្ឆ័យទោស ទាំងផែនដី ទាំងអ្វីៗ
ដែលនៅលើផែនដី[ប]ដែរ។

១១បើអ្វីៗទាំងនោះ មុខតែរលាយសូន្យ
យ៉ាងនេះទៅហើយ បងប្អូនត្រូវមានចរិយាដ៏
វិសុទ្ធនិងគោរពកោតខ្លាចព្រះជាម្ចាស់ ឲ្យមែន
ទែន!។១២ ចូរទន្ទឹងរង់ចាំ និងខ្នះខ្នែងធ្វើឲ្យ ថ្ងៃ
ដែលព្រះជាម្ចាស់ត្រូវយាងមកនោះ កាន់តែ
ឆាប់មកដល់ គឺជាថ្ងៃដែលផ្ទៃមេឃនឹងត្រូវឆេះ
រលាយ ហើយធាតុនានានឹងឆេះរលាយសូន្យ
អស់ទៅដែរ។ ១៣យើងទន្ទឹងរង់ចាំ ផ្ទៃមេឃថ្មី
និងផែនដីថ្មី[ឌ]ដែលប្រកបដោយសេចក្ដីសុចរិត[ឍ]
តាមព្រះបន្ទូលសន្យា។

១៤ដូច្នេះបងប្អូនជាទីស្រឡាញ់អើយ ក្នុង
ពេលដែលបងប្អូន ទន្ទឹងរង់ចាំហេតុការណ៍ទាំង
នេះ ចូរខ្នះខ្នែងធ្វើយ៉ាងណាឲ្យព្រះជាម្ចាស់
ឃើញថា បងប្អូនល្អឥតខ្ចោះ ឥតសៅហ្មង និង
ឃើញបងប្អូនរស់នៅដោយសុខសាន្ត។១៥តោង
យល់ថា ព្រះអម្ចាស់នៃយើងមានព្រះហឫទ័យ
អត់ធ្មត់មកពីព្រះអង្គចង់សង្គ្រោះបងប្អូន ដូច
លោកប៉ូល ជាបងប្អូនដ៏ជាទីស្រឡាញ់របស់
យើងបានសរសេរមកជូនបងប្អូន តាមប្រាជ្ញា
ដែលព្រះជាម្ចាស់ប្រទាន ឲ្យលោកស្រាប់ហើ
យ។ ១៦ក្នុងគ្រប់សំបុត្រដែលលោកបរិយាយ
អំពីរឿងទាំងនេះ លោកតែងតែសរសេរដូច្នេះឯ
ង។ ក្នុងសំបុត្រទាំងនោះមានសេចក្ដីខ្លះពិបាក
យល់ ធ្វើឲ្យអ្នកល្ងង់និងអ្នកដែលគ្មានជំនឿ
រឹងប៉ឹង បកស្រាយខុសអត្ថន័យដូចគេធ្លាប់បក
ស្រាយអត្ថបទគម្ពីរឯទៀតៗខុសន័យដែរ
បណ្ដាលឲ្យខ្លួនគេត្រូវវិនាសអន្តរាយ។

១៧រីឯបងប្អូនវិញ បងប្អូនជាទីស្រឡាញ់
អើយ បងប្អូនបានជ្រាបសព្វគ្រប់ជាមុនហើយ។
ដូច្នេះ ត្រូវប្រុងប្រយ័ត្នខ្លួនកុំបណ្ដោយជនពាល
នាំបងប្អូនឲ្យវង្វេង ហើយមិនត្រូវបាត់បង់គោល
ជំហរដ៏រឹងប៉ឹងរបស់បងប្អូនឡើយ។ ១៨ផ្ទុយទៅ
វិញ សូមបងប្អូនបានចម្រើនឡើង ដោយព្រះ
ហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់
ហើយដោយស្គាល់ព្រះយេស៊ូគ្រីស្ត* ជាព្រះ
អម្ចាស់ និងជាព្រះសង្គ្រោះរបស់យើងកាន់តែ
ខ្លាំងឡើងៗ។ សូមលើកតម្កើងសិរីរុងរឿងរបស់
ព្រះអង្គ នៅពេលឥឡូវនេះព្រមទាំងរហូតដល់
អស់កល្បជានិច្ចតរៀងទៅ។ អាម៉ែន។

*ក.មានន័យថាយើងជាបុត្រធីតារបស់ព្រះជាម្ចាស់។យើងអាចបកប្រែឃ្លានេះថា«ចូលរួមក្នុងសភាពជាព្រះជាម្ចាស់» ក៏បាន» ។•ខ. «កិរិយាល្អឥតខ្ចោះ» និង«ព្រះបារមី»(នៅ១៣)ក្នុងភាសាដើមជាពាក្យតែមួយ។ព្រះបារមីរបស់ព្រះជាម្ចាស់ជំរុញអ្នកជឿឲ្យមានកិរិយាល្អឥតខ្ចោះ។*

*គ. សូមអានម៉ាថាយ១៧.១–៨។*

*ឃ.ឃ្លាដើម«ការអន្តរាយរបស់គេមិនដេកលក់ទេ» ។•ង. យើងអាចប្រែពាក្យ«ទុក្ខលំបាក» នេះថា«លត់ដំ» ឬ«ការល្បងល» ក៏បាន។•ច.ពាក្យដើម«សិរីរុងរឿងនានា» ។•ឆ. ជំរឿនប្រជាជន២២. ៤–៣៥។*

ជ. ពាក្យដើម«រលួយ» យើងអាចប្រែពាក្យនេះថា: «សេចក្តីស្លាប់» ក៏បាន។•ឈ.សុភាសិត២៦.១១។ សុភាសិតនេះស្របនឹងពាក្យស្លោកខ្មែរថា«ឆ្កែកន្ទុយខ្វៀន» ។•ញ. ពោលគឺមិនវង្វេងទៅតាមពួកព្យាការីក្លែងក្លាយ។• ដ.ទំនុកតម្កើង៩០.៤។

ឋ. យើងអាចបកប្រែថា«น̀ផែនដីនិងអ្វីៗដែលនៅលើផែនដីក៏នឹងត្រូវឆេះអស់ទៅដែរ» ។•ឌ. អេសាយ៦៥.១៧;៦៦.២២។•ឍ.ឃ្លាដើម«ដែលមានសេចក្តីសុចរិតរស់នៅ» ។